# ភាពប្រឈមនៃសិល្បៈបុរាណនិងប្រពៃណីខ្មែរនាអនាគតកាល

ការផ្លាស់ប្តូរ និងបត់បែនមិនទាន់ស្ថានភាពនិងសភាពការ គឺមិនខុសអ្វីពីក្រុមហ៊ុនទូរស័ព្ទណូគា ដែលបាត់សាបសូន្យមិនមាននៅលើទីផ្សារសព្វថ្ងៃនេះ ក៏ព្រោះតែមិនបានផ្លាស់ប្តូរតាមសភាពការចរន្តដូច្នោះដែរ។ ដូចគ្នានេះ ទម្រង់សិល្បៈបុរាណនិងប្រពៃណីខ្មែរមួយចំនួនធំ មិនបានធ្វើបច្ចុប្បន្នភាវូបនីយកម្មនិងមានបច្ចុប្បន្នភាពទាន់ពេលវេលានិងកាលៈទេសៈ ពោលគឺធ្វើនិងរក្សានូវភាពដដែលៗ។

ទស្សនៈ ខ្ចីខ្ចឹម ប្លែកទំនើបរំភើបទាក់ទាញ អស្ចារ្យ ផ្ទុះ និងសកលភាវូបនីយកម្មតំបន់ភាវូបនីយកម្ម និងសមាហរណកម្មអាស៊ាន ជាបរិបទថ្មីដែលសិល្បៈខ្មែរត្រូវផ្ទុះបញ្ចាំង។ សិល្បករសិល្បការិនី ត្រូវ «គិតជាសកល ធ្វើជាខ្មែរ» ក្នុងទស្សនៈ «បុរាណមិនយឺត សម័យមិនបរទេស» ដើម្បីរក្សាអត្តសញ្ញាណខ្មែរ។

ជាមួយគ្នានេះ សិល្បៈបុរាណនិងប្រពៃណីខ្មែរ ក៏កំពុងប្រឈមនឹងប្រព័ន្ធបណ្តាញសង្គមឌីហ្ស៊ីថឹលសម័យជឿនលឿននិងសម្លូណ៌បែបនាពេលបច្ចុប្បន្ន ជាពិសេសតាមរយៈទូរសព្ទបញ្ញាដែលគ្រប់គ្នាមាននៅនឹងដៃ។

ពាក់ព័ន្ធនឹងការផ្សព្វផ្សាយនិងអប់រំប្រជាពលរដ្ឋ យើងនៅខ្វះកម្មវិធីផ្សព្វផ្សាយអប់រំពីសិល្បៈបុរាណនិងប្រពៃណីខ្មែរ ដើម្បីបញ្ជ្រាបនៅក្នុងសាធារណជន ជាពិសេសស្រទាប់យុវវ័យ។ ជាលទ្ធផល សិល្បៈបុរាណនិងប្រពៃណីខ្មែរ ខ្វះការគាំទ្រពីសាធារណជននិងយុវវ័យ។

លើសពីនេះទៅទៀត យើងគួរពិនិត្យឡើងវិញនូវទស្សនៈ «អភិរក្ស ថែរក្សា ទំនើបកម្មច្នៃប្រឌិត បង្កើតថ្មី នវានុវត្តន៍ និងអភិវឌ្ឍន៍» ថាតើយើងត្រូវធ្វើយ៉ាងដូចម្តេចនាអនាគតកាល? យើងស្គាល់ខ្លួនឯងនិងវប្បធម៌របស់ខ្លួនឯងច្បាស់ហើយឬនៅ? យើងបានកំណត់ទិសដៅច្បាស់ហើយឬនៅ? យើងនៅឯណា កំពុងធ្វើអី ទៅណា? គំនិតនិងទង្វើមួយទៀតក៏យើងគួរពិចារណាដែរ គឺគំនិត «សិល្បៈដើម្បីសិល្បៈ» និង «សិល្បៈដើម្បីលុយ» (Art for art sake versus Art for money sake)។ ជាមួយគ្នានេះ យើងក៏ត្រូវទទួលស្គាល់ការពិត គឺថា «ឆន្ទៈមិនអាចរំលងឬឈ្នះលទ្ធភាព» បានឡើយ។

អត្ថបទដោយ៖ បណ្ឌិត សំ សំអាង

នៅក្នុងសៀវភៅ *ទស្សនីយភាពខ្មែរ* (២០០៣) លោក ពេជ្រ ទុំក្រវិល បានកត់ត្រាសិល្បៈទស្សនីយភាពជាង២០ទម្រង់រួមមាន៖ ១) របាំក្បាច់បុរាណ ២) របាំប្រពៃណី ៣) របាំប្រជាប្រិយ ៤) សៀក ៥) ស្បែកធំ ៦) ស្បែកពណ៌ ៧) ស្បែកតូច ៨) ល្ខោនតុក្កតា ៩) ល្ខោនខោល ១០) ល្ខោនយីកេ ១១) ល្ខោនបាសាក់ ១២) ល្ខោនមហោរី ១៣) ល្ខោនកំណាព្យ ១៤) ល្ខោនពោលស្រី ១៥) ល្ខោនគែន ១៦) ល្ខោនបើកបទ ១៧) ល្ខោនបាមោជ្ជទ័យ ១៨) អាយ៉ៃ ១៩) ល្ខោនអាប៉េ ២០) ល្ខោនក្មេងការ ២១) ល្ខោននិយាយ ២២) ល្ខោនចម្រុះ ២៣) ការនិទានរឿង ២៤) ចម្រៀងចាប៉ី ២៥) តន្ត្រីខ្មែរ ២៦) តន្ត្រីខ្មែរលើ ២៧) សិល្បៈអន្តរជាតិនៅកម្ពុជា (របាំបាឡេ តន្ត្រីសម័យ តន្ត្រីសំឡេងស្រាល និងចម្រៀងជាពួក)។ យើងគួរកត់សម្គាល់ថា កម្ពុជាយើងក៏មានសិល្បៈល្ខោនគ្រាប់ផងដែរ។

ហេតុអ្វីបានជាទម្រង់ខ្លះក្នុងចំណោមទម្រង់ទាំងជាង២០ខាងលើនេះបានស្លាប់ ដូចជាល្ខោនកំណាព្យ ល្ខោនពោលស្រី ល្ខោនបាមោជ្ជទ័យ និងល្ខោនអាប៉េ ជាដើម? ហេតុអ្វីបានជារបាំក្បាច់បុរាណខ្មែរ មានភាពលូតលាស់រុងរឿង និងរស់រៀនមានជីវិត កេរ្តិ៍ឈ្មោះល្បីរន្ទឺសុះសាយ? ទាំងអស់នេះ គឺដោយសារការអប់រំ ផ្សព្វផ្សាយ បណ្តុះបណ្តាល យល់ដឹង ស្រឡាញ់គោរព ថែរក្សាលើកស្ទួយ អភិវឌ្ឍ និងបន្តវេនដោយទស្សនិកជននិងយុវជនយុវនារីខ្មែរយើង។

## ឯកសារពិគ្រោះ

ពេជ្រ ទុំក្រវិល.

(២០០៣). *ទស្សនីយភាពខ្មែរ*. ភ្នំពេញ: រដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា។

អត្ថបទដោយ៖ បណ្ឌិត សំ សំអាង



អត្ថបទដោយ៖ បណ្ឌិត សំ សំអាង